# ការវិភាគទៅលើមតិសាធារណៈ ស្ដីពី

## ការប្រើប្រាស់ ការនិយាយភាសាលាយឡំគ្នា ខ្មែរ-អង់គ្លេស ឬហៅថា Code-Switching

---

ការវិភាគលើមតិសាធារណៈចំនួន ៩៩០

ខែមេសា ឆ្នាំ២០២៦

របាយការណ៍នៃការសិក្សា

| ៩៩០ | ៤៦.៣% | ១៣.៦% |
|---|---|---|
| មតិសរុប | ទំនោរទៅ ភាពអវិជ្ជមាន | ទំនោរទៅ ភាពវិជ្ជមាន |

# សេចក្តីសង្ខេបរបាយការណ៍នៃការសិក្សា

នៅចុងខែមីនា ឆ្នាំ២០២៦ វីដេអូលើកទឹកចិត្តខ្លីមួយរបស់យុវតីខ្មែរម្នាក់ឈ្មោះ Keang Dee Kong ឬហៅថា KD ត្រូវបានចែកចាយយ៉ាងច្រើននៅលើបណ្តាញសង្គមហ្វេសប៊ុក ដោយសារតែនាងបាននិយាយលាយឡំគ្នារវាងភាសាខ្មែរ និងភាសាអង់គ្លេសដោយរលូន។ ការនិយាយបែបនេះ ត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជា «Khmerlish» (ខ្មែរលីស)។ ត្រឹមតែរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ការបង្ហោះនោះទទួលបានប្រតិកម្មជាសាធារណៈរាប់រយ ដែលបានធ្វើឱ្យកម្តៅនៃកិច្ចពិភាក្សាដេញដោលអំពីការប្រើប្រាស់ភាសាចម្រុះ (code-switching) អត្តសញ្ញាណភាសា និងរបៀបដែលយុវជនខ្មែរគួរនិយាយ ងើបឡើងវិញជាថ្មី។ ការសិក្សានេះ ធ្វើការវិភាគលើមតិសាធារណៈទាំង ៩៩០ ដែលមាននៅលើការបង្ហោះមាតិកាវិដេអូនោះ រួមជាមួយនឹងប្រតិចារឹកវីដេអូ (អត្ថបទសំឡេងទាំងស្រុងនៃវីដេអូ/video transcript) ដើម្បីពិពណ៌នាដោយផ្អែកលើទិន្នន័យជាក់ស្តែង ជាជាងការសន្មត នូវអ្វីដែលសាធារណជនបានលើកឡើង និងរបៀបដែលអ្នកនិយាយបានប្រើប្រាស់ភាសាពិតប្រាកដ។

មតិយោបល់នីមួយៗត្រូវបានអានយ៉ាងលម្អិតក្នុងបរិបទភាសាខ្មែរ និងអង់គ្លេស រួចចាត់ថ្នាក់ចូលទៅក្នុងប្រទេសនៃទំនោរ(អារម្មណ៍) (sentiment) ចំនួនប្រាំមួយ។ ចំពោះអត្ថបទសំឡេងនៃវីដេអូវិញ ត្រូវបានវិភាគដោយប្រើប្រាស់ការពិនិត្យមើលពី កម្រិតតួអក្សរ ពាក្យ និងព្យាង្គ ដើម្បីវាស់វែងនូវសមាមាត្រពិតប្រាកដរវាងភាសាខ្មែរ និងអង់គ្លេស។ ជាលទ្ធផល គេបានរកឃើញចំណុចសំខាន់ៗចំនួនបី៖

**ទីមួយ** ការពិភាក្សានៅលើបណ្តាញសង្គមអំពីការផុសនេះ មិនមែនមានតែសុទ្ធតែការរិះគន់គ្នាតែម្ខាងនោះទេ ពោលគឺ ៤៦,៣% នៃមតិយោបល់ គឺជាមតិប្រឆាំងនឹងអ្នកនិយាយ (ការចំអក ឬការប្រើពាក្យអសុរស) ប៉ុន្តែមាន ៣២,៣% បានផ្តល់ជាមតិក្នុងន័យស្ថាបនា និង ១៣,៦% ទៀតបានចេញមុខការពារ ឬគាំទ្រម្ចាស់មាតិកា។ នេះបង្ហាញថា សម្លេងដែលមានហេតុផល មានចំនួនប្រហាក់ប្រហែលនឹងសម្លេងដែលរិះគន់ក្នុងន័យអវិជ្ជមាន។

**ទីពីរ** ការរិះគន់ភាគច្រើនលើសលប់ គឺសំដៅទៅលើទម្រង់នៃការប្រើប្រាស់ភាសា (ការនិយាយលាយឡំគ្នា) ជាជាងការពិនិត្យពីខ្លឹមសារនៃសារលើកទឹកចិត្តរបស់ម្ចាស់មាតិកា។

**ទីបី** សម្តីដែលបានប្រើប្រាស់នៅក្នុងវីដេអូនោះ គឺភាគច្រើនជាភាសាខ្មែរ (ប្រហែល ៦០.៨% ជាភាសាខ្មែរ និង ៣៩.២% ជាភាសាអង់គ្លេស បើគិតតាមចំនួនព្យាង្គ)។

# ១. សេចក្តីផ្តើម និងបរិបទ

## ១.១ រឿងរ៉ាវនៅពីក្រោយទិន្នន័យ

មាតិកាវិដេអូដែលបានផ្សព្វផ្សាយ[1] កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ របស់ហ្វេសប៊ុកផេក ឈ្មោះ DK គឺជាកម្មវត្ថុចម្បងនៃការសិក្សានេះ គឺផ្អែកលើវីដេអូខ្លីលើកទឹកចិត្តមួយ ដែលត្រូវបានបង្ហោះលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) នាដើមឆ្នាំ២០២៦ ដោយយុវតីខ្មែរម្នាក់។ នៅក្នុងវីដេអូនោះ ម្ចាស់មាតិកាបានរៀបរាប់ពីរឿងរ៉ាវនៃការបរាជ័យរបស់ខ្លួននៅចំពោះមុខសិស្សានុសិស្សចំនួន ១.០០០ នាក់ ហើយបានប្រើប្រាស់បទពិសោធន៍នោះដើម្បីលើកទឹកចិត្តអ្នកដទៃឱ្យជម្នះភាពភ័យខ្លាចក្នុងការនិយាយជាសាធារណៈ។ នាងបានផ្ញើសារនោះតាមរយៈរបៀបនិយាយបែបធម្មជាតិរបស់នាង ដែលជាការប្រើប្រាស់លាយឡំគ្នារវាងភាសាខ្មែរ និងភាសាអង់គ្លេស។

ត្រឹមតែរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ផ្នែកនៃការបញ្ចេញមតិ (Comment section) បានក្លាយទៅជាសមរភូមិវែកញែកយ៉ាងក្តៅគគុក ដែលមិនមែនផ្តោតលើខ្លឹមសារនៃសារនោះទេ ប៉ុន្តែគឺផ្តោតលើភាសារបស់នាងទៅវិញ។ មនុស្សរាប់រយនាក់បានចូលមកបញ្ចេញមតិក្នុងន័យចំអក រិះគន់ ការពារ ឬគាំទ្រនាង ដែលធ្វើឱ្យការបង្ហោះនេះក្លាយជាផូសដ៏លេចធ្លោបំផុតមួយដែលមានចំនួនចូលរួម (Engagement) របស់ហ្វេសប៊ុកផេកនេះ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២៤ ដែលការកិច្ចពិភាក្សាដេញដោលនេះកំពុងបន្តច្រើនឡើងៗនៅលើបណ្តាញសង្គមក្នុងប្រទេសកម្ពុជា អំពីការប្រើប្រាស់ភាសា «Khmerlish» (ខ្មែរលីស)។

## ១.២ តើអ្វីទៅជាការប្រើប្រាស់ភាសាចម្រុះ (Code-switching)

ការប្រើប្រាស់ភាសាចម្រុះ (Code-switching[2]) គឺជាបាតុភូតដែលអ្នកនិយាយទ្វិភាសា (Bilingual) ផ្លាស់ប្តូរទៅមករវាងភាសាពីរ ក្នុងកិច្ចសន្ទនា/ការនិយាយតែមួយ។ ជួនកាល ការផ្លាស់ប្តូរនេះកើតឡើងនៅចន្លោះល្បះ (ឧទាហរណ៍៖ “I’m going to the market. ចង់ទិញអីទេ?”) និងជួនកាលទៀត កើតឡើងនៅក្នុងល្បះតែមួយតែម្តង (ឧទាហរណ៍៖ “I need that fire to បណ្តុះ conviction”)។

អ្នកស្រាវជ្រាវនៅតែមានទស្សនៈខុសគ្នា ចំពោះរបៀបនៃការមើលឃើញលើឥរិយាបថនេះ៖ អ្នកខ្លះចាត់ទុកវាថាជាសញ្ញានៃភាពទន់ខ្សោយ ឬកង្វះភាពស្ទាត់ជំនាញក្នុងភាសាគោល ខណៈពេលដែលការសិក្សាស្រាវជ្រាវកាន់តែច្រើនឡើងបានអះអាងថា វាគឺជាយុទ្ធសាស្ត្រទំនាក់ទំនងដោយចេតនាមួយ ដែលត្រូវបានប្រើប្រាស់ដោយអ្នកនិយាយដែលមានសមត្ថភាពខ្ពស់ក្នុងភាសាទាំងពីរ ជាជាងការខ្វះខាតផ្នែកភាសា (Hasibuan & Sari, 2018)[3]។ អ្នកនិយាយប្រើប្រាស់វិធីនេះ ដើម្បីស្វែងរកពាក្យពេចន៍ឱ្យចំអត្ថន័យច្បាស់លាស់ ដើម្បីបង្ហាញពីអត្តសញ្ញាណ ដើម្បីផ្ញើសារទៅកាន់ក្រុមមនុស្សដែលមានចំណេះដឹងភាសាផ្សេងគ្នា ឬដោយសារតែវាជាសម្លេងធម្មតានៃពិភពលោកដែលពួកគេរស់នៅប្រចាំថ្ងៃតែម្តង។

---

[1] Keang Dee Kong (2026, March 27). *Failure makes you grow!* Facebook. https://www.facebook.com/reel/962355646367946

[2] Code-switching definition. https://www.oed.com/dictionary/code-switch_v

[3] Hasibuan, A. A., & Sari, R. R. (2018). The functions of code switching in second language learning classroom. *[International Journal of Language and Linguistics, Vol. 5, No. 4, December 2018, page 100].* https://ijllnet.thebrpi.org/journals/Vol_5_No_4_December_2018/12.pdf

## ១.៣ តើអ្វីទៅជាការប្រើប្រាស់ «Khmerlish» (ខ្មែរលីស)

ពាក្យ «Khmerlish» (ខ្មែរលីស) គឺជាឈ្មោះហៅក្រៅបែបសាមញ្ញសម្រាប់ការប្រើប្រាស់ភាសាចម្រុះតាមបែបកម្ពុជា ពោលគឺការលាយឡំគ្នារវាងភាសាខ្មែរ និងអង់គ្លេស ដែលគេតែងតែឮជាទូទៅនាពេលបច្ចុប្បន្ន នៅក្នុងការិយាល័យនានា ការធ្វើបទបង្ហាញ ក្នុងថ្នាក់រៀន វីដេអូយូធូប (YouTube) និងក្នុងក្រុមនិយាយគ្នាក្នុងឆែត (chat) របស់ក្រុមគ្រួសារឬមិត្តភក្តិជាដើម។ ការប្រើប្រាស់នេះមានភាពពេញនិយមជាពិសេសក្នុងចំណោមយុវជនខ្មែរដែលរស់នៅតាមទីប្រជុំជន សិស្សដែលរៀននៅសាលាចំណេះដឹងទូទៅដែលប្រើប្រាស់ភាសាអង់គ្លេស អ្នកដែលត្រឡប់មកពីបរទេស និងអ្នកជំនាញក្នុងវិស័យអាជីវកម្ម បច្ចេកវិទ្យា អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា[4]។ មតិយោបល់ចំពោះភាសា «Khmerlish» ត្រូវបានបែងចែកជាពីរ។ បញ្ញវន្ត និងបុគ្គលសាធារណៈខ្មែរមួយចំនួនបានអះអាងថា ការប្រើប្រាស់ភាសាចម្រុះ (code-switching) បានធ្វើឱ្យធ្លាក់ចុះនូវតម្លៃនៃភាសាខ្មែរ ហើយគួរតែត្រូវបានជៀសវាងនៅក្នុងកម្មវិធីផ្លូវការ ឬទីសាធារណៈ[5]។ រីឯអ្នកផ្សេងទៀត រួមទាំងអ្នកអប់រំបែបទ្វិភាសាផងដែរនោះ បានពិពណ៌នាថាវាគឺជាទម្លាប់នៃការនិយាយបែបធម្មជាតិ ដែលត្រូវបានបង្កើតឡើងតាមរយៈការប្រើប្រាស់ភាសាច្រើនជាងមួយនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

## ១.៤ គោលបំណងនៃការសិក្សា

ការសិក្សានេះបានដកស្រង់ការបង្ហោះដែលកំពុងល្បីខ្លាំង (viral) នោះមកធ្វើជាករណីសិក្សា និងលើកឡើងនូវសំណួរជាក់លាក់ចំនួនបី៖

**១.** តើការបែងចែកនៃប្រតិកម្មសាធារណៈពិតប្រាកដមានលក្ខណៈបែបណា នៅពេលដែលរាល់មតិយោបល់នីមួយៗត្រូវបានអានយ៉ាងលម្អិតទៅតាមបរិបទ ជាជាងគ្រាន់តែការពិនិត្យមើលតាមពាក្យគន្លឹះ?

**២.** តើអ្នកបញ្ចេញមតិពិតជាកំពុងរិះគន់ទៅលើអ្វីឱ្យប្រាកដ ទម្រង់នៃភាសារបស់អ្នកនិយាយ ឬក៏ខ្លឹមសារនៃសាររបស់នាង?

**៣.** តើសមាមាត្រពិតប្រាកដរវាងភាសាខ្មែរ និងអង់គ្លេស នៅក្នុងការនិយាយនោះមានកម្រិតណា?

គោលដៅនៃការសិក្សានេះ មិនមែនដើម្បីជ្រើសរើសភាគីណាមួយនៅក្នុងការជជែកដេញដោលអំពីភាសា «Khmerlish» នោះទេ ប៉ុន្តែគឺដើម្បីផ្តល់ជូនសាធារណជននូវរូបភាពដែលផ្អែកលើភស្តុតាងជាក់ស្តែង អំពីរបៀបដែលការជជែកដេញដោលនោះកំពុងវិវត្តទៅនាឆ្នាំ២០២៦។

---

[4] *ការលើកឡើងនេះ គឺជាការសង្កេតផ្ទាល់របស់អ្នកសរសេរ និងវិភាគរបាយការណ៍ ចំពោះការប្រើប្រាស់ភាសា «Khmerlish» (ខ្មែរលីស)។ ការអង្កេតនេះគួរចាត់ទុកថាជាបរិបទក្រៅផ្លូវការ ជាជាងលទ្ធផលដែលបានមកពីការសិក្សា។*

[5] Meng Seavmey (2024, March 20). Shared Languages Send Mixed Messages. https://cambodianess.com/article/shared-languages-send-mixed-messages

# ២. វិធីសាស្ត្រសិក្សា

## ២.១ ប្រភពទិន្នន័យ

សំណុំទិន្នន័យចំនួនពីរត្រូវបានប្រមូលចេញពីការបង្ហោះលើហ្វេសប៊ុកផ្ទសតែមួយ៖

**(ក)** សំណុំទិន្នន័យរបស់មតិសាធារណៈចំនួន ៩៩០ (ចំនួនទិន្នន័យក្រោយពេលសំអាត) ដែលរួមមានឈ្មោះគណនី សំណេរមតិ និងចំនួនអ្នកចុចចូលចិត្ត (Like)

**(ខ)** អត្ថបទសំឡេងតាមសម្ដីពិត (transcript) នៃវីដេអូរបស់អ្នកនិយាយ ដែលត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយសំឡេងដើម ដើម្បីរក្សានូវអក្ខរាវិរុទ្ធភាសាខ្មែរ អក្ខរាវិរុទ្ធភាសាអង់គ្លេស និងលំដាប់លំដោយពិតប្រាកដនៃការប្រើប្រាស់ភាសាចម្រុះ។

## ២.២ ការបែងចែកប្រភេទមនោសញ្ចេតនា

មតិនីមួយៗក្នុងចំណោម ៩៩០ ត្រូវបានអានដោយយ៉ាងលម្អិតទៅតាមបរិបទភាសាខ្មែរ និងអង់គ្លេស រួចចាត់ចូលទៅក្នុងប្រភេទនិមួយៗ ក្នុងចំណោមប្រភេទមតិទាំងប្រាំមួយ រួមមាន៖ ការគាំទ្រ (Supportive), ការរិះគន់ក្នុងន័យស្ថាបនា (Constructive Criticism), ការចំអក/ការបង្អាប់ (Mocking/Ridicule), ការប្រឆាំង/ការប្រើពាក្យអសុរស (Hostile/Aggressive), មតិអព្យាក្រឹត/ការសង្កេត (Neutral/Observational) និងការការពារអ្នកនិយាយ (Defensive)។ ការចាត់ថ្នាក់នេះត្រូវបានផ្អែកលើន័យច្បាស់លាស់របស់អ្នកសរសេរមតិទាំងស្រុង ដោយមិនបានផ្អែកលើការពិនិត្យមើលតែពាក្យគន្លឹះនីមួយៗនោះទេ។

## ២.៣ ការវិភាគពីសមាមាត្រភាសានៃអត្ថបទសំឡេង(Transcript)

អត្ថបទសំឡេង (transcript) ត្រូវបានវាស់វែងរកតុល្យភាពរវាងភាសាខ្មែរ និងអង់គ្លេស តាមបីរបៀប៖ តាមរយៈការរាប់ចំនួនតួអក្សរ (ដោយចាត់ទុកតួអក្សរខ្មែរយូនីកូដជាភាសាខ្មែរ), តាមរយៈការរាប់ចំនួនពាក្យដែលបំបែកដោយចន្លោះ (Whitespace), និងតាមរយៈការរាប់ដែលតម្រូវតាមព្យាង្គ ដែលចាត់ទុកការផ្សំតួអក្សរខ្មែរនីមួយៗថាមានតម្លៃប្រហាក់ប្រហែលនឹងពាក្យអង់គ្លេសមួយ។ វិធីសាស្ត្ររាប់តាមព្យាង្គ គឺជាវិធីសាស្ត្រដែលបង្ហាញពីភាពត្រឹមត្រូវទៅនឹងអ្វីដែលគេបានឮជាក់ស្តែង ព្រោះថាភាសាខ្មែរសរសេរមិនមានដកឃ្លា ហើយឃ្លាខ្មែរខ្លីមួយអាចមានចំនួនព្យាង្គស្មើនឹងពាក្យអង់គ្លេសជាច្រើន។

## ២.៤ ទំហំ និងកម្រិតនៃការសិក្សា

នេះគឺជាការសិក្សាករណីតែមួយ (Single-case study) លើការផុសក្នុងផេក [https://www.facebook.com/reel/962355646367946](https://www.facebook.com/reel/962355646367946) តែមួយប៉ុណ្ណោះ។ លទ្ធផលដែលរកឃើញ គឺរៀបរាប់អំពីខ្លឹមសារពីការជជែកដេញដោលនេះ ហើយវាមិនគួរត្រូវបានចាត់ទុកថាជាការស្ទង់មតិតំណាងឱ្យកម្រិតជាតិទាំងមូលនោះទេ។ មានតែមតិយោបល់ ដែលមើលឃើញចាប់បីថ្ងៃទី២៧ ខែមីនា រហូតដល់ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៦ប៉ុណ្ណោះ ដែលត្រូវបានដាក់បញ្ចូលក្នុងការវិភាគ។ ដោយសារតែមានតែម្នាក់ឯងជាអ្នកអាន និងចាត់ថ្នាក់មតិទាំង ៩៩០ ការវិនិច្ឆ័យតាមបែបផ្ទាល់ខ្លួនបន្តិចបន្តួចចំពោះប្រភេទនៃមតិគឺមិនអាចចៀសផុតឡើយ។ នៅពេលណាដែលមតិមួយអាចមានលក្ខណៈសមស្របនឹងប្រភេទមតិលើសពីមួយ មតិនោះនឹងត្រូវបានចាត់ចូលទៅក្នុង

ប្រភេទដែលមានន័យអវិជ្ជមានតិចតួចជាងគេបំផុត ដូច្នេះលទ្ធផលដែលទទួលបាន គឺផ្អែកលើការប្រុងប្រយ័ត្នខ្ពស់ជាងការបំផ្លើសការពិត។

# ៣. លទ្ធផលនៃការសិក្សា

## ៣.១ ការបែងចែកនៃប្រតិកម្មសាធារណៈ

មតិនីមួយៗក្នុងចំណោម ៩៩០ ត្រូវបានអានយ៉ាងលម្អិត និងចាត់ថ្នាក់ទៅក្នុងប្រភេទមួយក្នុងចំណោមប្រភេទទាំងប្រាំមួយ ផ្អែកលើសកម្មភាពពិតប្រាកដរបស់អ្នកសរសេរមតិ ទោះជាការចំអក ការរិះគន់ ការវាយប្រហារ ការការពារ ការសង្កេត ឬការគាំទ្រ។ លេខនៅក្នុងរង្វង់ក្រចក គឺជាចំនួនរាប់ជាក់ស្តែង។



## ៣.២ កម្រិតនៃការចូលរួម (Engagement)៖ តើសំឡេងណាដែលជះឥទ្ធិពលខ្លាំងជាងគេ

មិនមែនរាល់មតិយោបល់ទាំងអស់សុទ្ធតែមានទម្ងន់ស្មើគ្នានោះទេ។ មតិដែលមានអ្នកចុចចូលចិត្ត (Like) ចំនួន ២០០ នឹងត្រូវបានមើលឃើញដោយមនុស្សច្រើនជាងមតិដែលគ្មានអ្នកចុច Like ទាល់តែសោះ។ តារាងខាងក្រោមបង្ហាញអំពីចំនួនមតិនៅក្នុងប្រភេទនីមួយៗ ចំនួនអ្នកចុចចូលចិត្តសរុបដែលមតិទាំងនោះទទួលបាន និងចំនួនមធ្យមនៃអ្នកចុច Like ក្នុងមតិមួយៗ។ ចំណុចដែលគួរកត់សម្គាល់គឺ៖ មតិអវិជ្ជមានខ្លីៗ (Hostile) មានចំនួនតិចតួច (១០,៤%) ប៉ុន្តែទទួលបានចំនួនអ្នកចុចចូលចិត្តមធ្យមខ្ពស់ជាងគេបំផុត (មធ្យម ៧,៤ ក្នុងមួយមតិ)។ នេះហើយគឺជាមូលហេតុដែលធ្វើឱ្យបរិយាកាសនៃការជជែកដេញដោលក្នុងផ្នែកមតិយោបល់នេះ មើលទៅហាក់ដូចជាមានភាពកាចសាហាវខ្លាំង លើសពីទិន្នន័យនៃចំនួនមតិជាក់ស្តែងដែលបានបង្ហាញ។

| ប្រភេទ | ចំនួន | ចំនួន Like សរុប | មធ្យមភាគនៃចំនួន Like | ការចូលរួម |
|---|---|---|---|---|
| ការចំអក/ការបង្អាប់ | ៣៥៧ | ១២៦២ | ៣.៥ | មធ្យម |
| ការរិះគន់ក្នុងន័យស្ថាបនា | ៣២០ | ១០៦០ | ៣.៣ | មធ្យម |
| ការប្រឆាំង/ការប្រើពាក្យអសុរស | ១០៣ | ៧៦២ | ៧.៤ | មធ្យម |
| ការការពារ (ខាងអ្នកនិយាយ) | ៩១ | ២៨៤ | ៣.១ | មធ្យម |
| អព្យាក្រឹត/ការសង្កេត | ៧៥ | ៤០ | ០.៥ | ទាប |
| ការគាំទ្រ | ៤៤ | ២៥ | ០.៦ | ទាប |

### មតិដើមដែលមានការចូលរួមច្រើន vs. ការចូលរួមតិច

> *"និយាយខ្មែរផង speak english also មនុស្សស្រុកខ្មែរគេនិយាយថា what about you j+o"*
> — Comment #1 · Hostile · 594 likes

> *"Hi Sister! I've noticed that you switch between English and Khmer quite frequently. If it is difficult to find the right words in Khmer, it might be better to speak entirely in English rather than switching back and forth. This isn't just about 'Gen Z' trends; in many other countries, young peo..."*
> — Comment #371 · Constructive · 526 likes

> *"និយាយចឹង ខ្មែរដែលគាត់មិនចេះអង់គ្លេសក៏ស្តាប់មិនយល់ ជនជាតិក៏អត់យល់😁😁😁 សូម្បីតែលោកបងចេះអង់គ្លេសតិចៗពិបាកនឹងយល់ដែរ 🤣"*
> — Comment #104 · Mocking · 281 likes

> *"បើស្តាប់មិនចូលត្រចៀក អូសចេញទៅ ហត់មេសលោកអើយ Comment ជេរ ដៀលគេធ្វើអី ?? អត់សម video គាត់ស្តាប់បានតែពាក់កណ្តាលមិនបានស្តាប់ពេញ ចឹងយើងមិនយល់ពីប្រធានបទគេនិយាយអីទេ មួយទៀត ពាក្យខ្មែរខ្លះ បើបកទៅ English វិញវាមិនសូវត្រូវន័យដែរ យើងចង់បាន ចឹងខ្មែរលាយ English ដើម្បីឲ្យអ្នកស្តាប់ហ្នឹងយល់ន័យសង្កត់ន័យបានលឿន។ not..."*
> — Comment #978 · Defensive · 97 likes

> *"ខ្ញុំមកអានខំមិន"*
> — Comment #475 · Neutral · 5 likes

> *"បងនិយាយ so confèden"*
> — Comment #540 · Supportive · 1 like

## ៣.៣ អាកប្បកិរិយាអវិជ្ជមានគ្របដណ្ដប់ច្រើន ប៉ុន្តែមិនគ្រប់លើសាច់រឿងទាំងស្រុងនោះទេ

ជិតពាក់កណ្ដាលនៃការបញ្ចេញមតិ (៤៦,៣% ឬ ៤៥៨ ក្នុងចំណោម ៩៩០ មតិ) គឺជាមតិដែលបង្ហាញភាពប្រឆាំងនឹងអ្នកនិយាយដោយចំហ រាប់ចាប់ពីការចំអក ការនិយាយតម្រាប់តាមក្នុងន័យបង្អាប់/កំប្លែង ឬការវាយប្រហារលើរូបនាងផ្ទាល់។ បើយើងពិនិត្យមើលតែពីមតិក្នុងប្រភេទ ចំអក គឺមានចំនួនច្រើនជាងគេបំផុត (៣៦,១%) បើធៀបនឹងប្រភេទមតិផ្សេងៗទៀតនៅក្នុងករណីនេះ។

ទោះជាយ៉ាងណា គំនូសតាង ខាងក្រោម បង្ហាញពីទិដ្ឋភាពទាំងស្រុងថា៖ មតិ ៥៣,៧% ផ្សេងទៀតនៃបញ្ចេញមតិគឺកំពុងធ្វើសកម្មភាពផ្សេងស្រឡះពីគ្នា រួមមានការផ្ដល់ដំបូន្មាន ការចេញមុខការពារ ការលើកទឹកចិត្ត ឬគ្រាន់តែជាការចូលមកសង្កេតមើល/ការយល់ឃើញទូទៅ។ ដូច្នេះ រាល់ការលើកឡើងណាដែលថា ការជជែកដេញដោលនេះគឺជា "ការព្រួតគ្នាវាយប្រហារ" តែម្ខាង គឺជាការរៀបរាប់តែមួយជ្រុងនៃអ្វីដែលបានកើតឡើងពិតប្រាកដប៉ុណ្ណោះ។




### មតិដើម ដែលផ្ទុកន័យលើសពីអវិជ្ជមាន

> *"មិនដឹងជាស្អីៗទេ អោយឡើងរ៉ុល! ខ្មែរមិនចំខ្មែរ បរទេសមិនចំបរទេស ហត់ម៉េស🤧😪😱"*
> — Comment #106 · Mocking · 148 likes

> *"ភាសាមនុស្សឆ្កួត! (ខ្មែរស្ដាប់អត់បាន បរទេសស្ដាប់ក៏អត់យល់ តែមនុស្សឆ្កួតស្ដាប់ប្រហែលយល់)។ កាលមុនគេរិះគន់ខ្លាំងស្មានតែកែបានខ្លះ ដឹងអីលេ ីសដេ ីម។ នេះគេហៅថា ផ្ដេ ីន!"*
> — Comment #2 · Hostile · 55 likes

> *"As I think you should speak clearly only one language in public speaking. Khmer 90% English 10% or English 90% Khmer 10%.But I understand your advice"*
> — Comment #372 · Constructive · 139 likes

> *"នាងជានារី គំរូនិងពូកែ ! បញ្ញាវ័ន្តអាយុក្រោម 40 សុទ្ធតែអាចស្ដាប់យល់របៀបដែលនាងនិយាយ ព្រោះសព្វថ្ងៃក្មេងៗចូលចិត្តនិយាយលាយលំបែបនេះ។ យើងចាស់ៗបត់មិនទាន់សង្គម ក៏អាចមិនពេញចិត្តនឹងរឿងនេះ។"*
> — Comment #894 · Defensive · 92 likes

> *"Maybe you should focus on the good informations and not on how she speaks. What's being shared is what matters."*
> — Comment #383 · Defensive · 6 likes

> *"ពាក្យខ្លះអត់ចេះខ្មែរ ពាក្យខ្លះអត់ចេះអង់គ្លេស ពេលចឹងទាល់តែនិយាយលាយគ្នាទើបនិយាយចេញ😌"*
> — Comment #135 · Neutral · 2 likes

## ៣.៤ ការរិះគន់ផ្ដោតលើរបៀបនៃការនិយាយ មិនមែនខ្លឹមសារ

នៅពេលយើងពិនិត្យឱ្យស៊ីជម្រៅទៅលើអ្វីដែលមតិប្រឆាំងអ្នកនិយាយទាំង ៤៥៨ ដែលបានខឹងសម្បារនោះ យើងឃើញថា ស្ទើរតែគ្មានមតិណាមួយជំទាស់នឹងអត្ថន័យសារលើកទឹកចិត្តរបស់នាងឡើយ តែមតិទាំងនោះជំទាស់នឹងរបៀបនិយាយរបស់នាងទៅវិញ។ មតិភាគច្រើនគឺចង់ឱ្យនាង «និយាយតែភាសាខ្មែរ» ឬ «និយាយតែភាសាអង់គ្លេស» ពោលគឺការនិយាយលាយឡំគ្នាត្រូវបានចាត់ទុកមុនថាជា «កំហុស»ទៅហើយ។ នេះគឺជាអំណះអំណាងបែបអភិរក្សភាសានិយមដ៏ពេញនិយម (Language Purism) ហើយនៅក្នុងការបញ្ចេញមតិនេះ វាគឺជាមូលហេតុចម្បងបំផុតដែលនាំឱ្យមនុស្សមានប្រតិកម្មអវិជ្ជមាន។

### ការសង្កេតសំខាន់៖

ទិន្នន័យនេះបង្ហាញពីគម្លាតរវាង ខ្លឹមសារ (Substance) និង ទម្រង់នៃរបៀបនិយាយ (Form of speech)។ មហាជនភាគច្រើនមិនបានបដិសេធតម្លៃនៃមេរៀនជីវិតដែលនាងបានចែករំលែកនោះទេ ប៉ុន្តែពួកគេមានភាពរសើបខ្លាំងទៅនឹងការប្រើប្រាស់អត្តសញ្ញាណភាសា ដែលពួកគេយល់ថាគួរតែរក្សាឱ្យបានហ្មត់ចត់បំផុត។

| ៤៥៨ | **មតិដែលផ្ដោតលើរបៀបនៃការនិយាយ ប៉ុន្តែមិនផ្ដោតលើខ្លឹមសារ**<br>*មតិប្រឆាំងអ្នកនិយាយទាំង ៤៥៨ សុទ្ធតែរិះគន់ទៅលើរបៀបដែលនាងនិយាយ ប៉ុន្តែស្ទើរតែគ្មានមតិណាមួយចូលរួមជជែកអំពីអ្វីដែលនាងបានលើកឡើងពិតប្រាកដ ពាក់ព័ន្ធនឹងការយកឈ្នះលើការភ័យខ្លាចក្នុងការនិយាយជាសាធារណៈនោះឡើយ។* |
|---|---|

### ការរិះគន់ទូទៅ គឺផ្ដោតទៅលើរបៀបដែលនាងនិយាយ ជាជាងអ្វីដែលនាងបាននិយាយ៖

> *"ជេរ បើនិយាយ English អោយចំEnglish ទៅ បេើនិយាយខ្មែរអោយចំខ្មែរទៅ"*
> — Comment #3 · Hostile · 41 likes

> *"ទេ រាចី បើនិយាយអង់គ្លេស ឲ្យចំអង់គ្លេសទៅ ដឹងប្រកាច់អីទេ"*
> — Comment #107 · Mocking · 133 likes

> *"Khmer ❌ English ❌ Khmerlish ✅ "Do you understand the words coming out of my mouth?"😂"*
> — Comment #108 · Mocking · 102 likes

> *"ម៉េចបានជាជនជាតិអាមេរិកនិយាយអង់គ្លេសអត់លាយខ្មែរចឹង"*
> — Comment #110 · Mocking · 28 likes

> *"អង់គ្លេសតុងខ្មែរដដែល មិននិយាយខ្មែរទៅ😪"*
> — Comment #374 · Mocking · 32 likes

## ៣.៥ ការរិះគន់ក្នុងន័យស្ថាបនា គឺជាមតិយោបល់ធំជាងគេទីពីរ

ជិតមួយភាគបីនៃកិច្ចសន្ទនា (៣២,៣% ឬ ៣២០ មតិ) មិនមែនជាការវាយប្រហារនោះទេ ប៉ុន្តែគឺជាការផ្តល់ដំបូន្មានដោយស្មោះត្រង់។ អ្នកសរសេរទាំងនេះបានស្នើឱ្យអ្នកនិយាយជ្រើសរើសយកភាសាតែមួយ គិតគូរដល់គោលដៅអ្នកស្តាប់ ឬប្រើប្រាស់ភាសាចម្រុះឱ្យមានភាពប្រុងប្រយ័ត្នជាងមុន ដែលមតិទាំងនេះច្រើនតែត្រូវបានសរសេរជារកថាខណ្ឌវែងៗ និងមានការត្រិះរិះពិចារណាខ្ពស់។

### មតិដើម របស់មតិដែលផ្តល់ការស្ថាបនា

> *"Hi Sister!  I've noticed that you switch between English and Khmer quite frequently. If it is difficult to find the right words in Khmer, it might be better to speak entirely in English rather than switching back and forth.  This isn't just about 'Gen Z' trends; in many other countries, young peo..."*
>
> — Comment #371 · Constructive · 526 likes

> *"នៅពេលដែលយុវជនឈប់ប្រើពាក្យខ្មែរសាមញ្ញៗ ហើយជំនួសដោយពាក្យបរទេសជាទម្លាប់  វាក៏អាចឈានទៅដល់ការអសមត្ថភាពក្នុងការប្រើភាសាខ្មែរឱ្យបានត្រឹមត្រូវ។   នៅពេលពួកគេត្រូវការសរសេរអត្ថបទផ្លូវការ ឬការវិភាគស៊ីជម្រៅ ពួកគេនឹងជួបវិបត្តិរកពាក្យខ្មែរមិនឃើញ។  ម្យ៉ាងទៀតការណ៍ដែលភាសាខ្មែរមានពាក្យប្រើហើយ តែមិនព្រមប្រ..."*
>
> — Comment #373 · Constructive · 121 likes

> *"My  3 years old daughter , She knows khmer and Spanish.  តែគាត់មិនដែល និយាយពីរភាសារជាមួយខ្ញុំទេ គឺខ្មែរសុទ្ធ  ពេលនិយាយជាមួយ ប៉ាគាត់គឺ អេស្ប៉ាញសុទ្ធ  Logic :she knows her target listener."*
>
> — Comment #469 · Constructive · 26 likes

> *"កាលខ្ញុំធ្វើការក្រុមហ៊ុន ថ្នាក់ដឹកនាំលំដាប់ប្រធាននាយកដ្ឋាន ឬនាយកប្រតិបត្តិ គេប្រើភាសាខ្មែរលាយអង់គ្លេសដែរ តែភាគតិចណាស់ ហើយប្រើសំខាន់តែចំពោះពាក្យណាដែលពិបាកបកប្រែអោយត្រូវន័យក្នុងភាសាខ្មែរ។ ក្រុមហ៊ុនមានទំនាក់ទំនងជាមួយភ្ញៀវបរទេសមកពីប្រទេសប្រើភាសាផ្សេងៗគ្នា។ ហើយភ្ញៀវទាំងនោះគេអោយតម្លៃទៅលើការប្រើភាសាណា..."*
>
> — Comment #376 · Constructive · 15 likes

> *"If you speak only one language is better than , if English please speak English, if Khmer, please Khmer"*
>
> — Comment #379 · Constructive · 8 likes

> *"ប្រសិនជាចែករំលែកឱ្យតែអ្នកចេះអង់គ្លេសស្តាប់ ខ្ញុំស្នើឱ្យនិយាយអង់គ្លេសសុទ្ធតែម្តងទៅ ខ្ញុំជឿថាគេនឹងសរសើរច្រើនវិញ"*
>
> — Comment #473 · Constructive · 7 likes

## ៣.៦ មតិការពារ មានសម្លេងតិចជាងគេ

ក្រុមអ្នកបញ្ចេញមតិដែលឈរនៅខាងអ្នកនិយាយគឺពិតជាមាន ប៉ុន្តែពួកគេគ្រាន់តែមិនសូវបញ្ចេញសម្លេងខ្លាំងៗប៉ុណ្ណោះ។ មតិដែលបង្ហាញពីការគាំទ្រ (៤,៤%) និងការចេញមុខការពារ (៩,២%) បូកបញ្ចូលគ្នាមានចំនួន ១៣,៦% នៃកិច្ចសន្ទនាទាំងមូល។

### មតិដើម នៃមតិដែលការពារ អ្នកនិយាយ

> *"បើស្តាប់មិនចូលត្រចៀក អូសចេញទៅ ហត់មេសលោកអើយ Comment ជេរ ដៀលគេធ្វើអី ?? អត់សម video កាត់ស្តាប់បានតែពាក់កណ្តាលមិនបានស្តាប់ពេញ ចឹងយើងមិនយល់ពីប្រធានបទគេនិយាយអីទេ មួយទៀត ពាក្យខ្មែរខ្លះ បើបកទៅ English វិញវាមិនសូវត្រូវន័យដែរ យើងចង់បាន ចឹងខ្មែរលាយ English ដើម្បីឲ្យអ្នកស្តាប់ហ្នឹងយល់ន័យសង្កត់ន័យបានលឿន។ not..."*

— Comment #978 · Defensive · 97 likes

> *"នាងជានារី គំរូនិងពូកែ ! បញ្ហាវ័ន្តអាយុក្រោម 40 សុទ្ធតែអាចស្តាប់យល់របៀបដែលនាងនិយាយ ព្រោះសព្វថ្ងៃក្មេងៗចូលចិត្តនិយាយលាយលំបែបនេះ។ យើងចាស់ៗបត់មិនទាន់សង្គម ក៏អាចមិនពេញចិត្តនឹងរឿងនេះ។"*
>
> — Comment #894 · Defensive · 92 likes

> *"I understand her fine tho? Maybe y'all are just slow😆"*
>
> — Comment #113 · Defensive · 8 likes

> *"There's nothing wrong with them. I also like to have a conversation with people by using mixed language khmer & English. Just be kind and stay positive everyone."*
>
> — Comment #979 · Defensive · 9 likes

> *"Guy!! Relax if you can't understand her, you're not her target audiences 😎"*
>
> — Comment #384 · Defensive · 5 likes

## ៣.៧ អត្ថបទសំឡេង៖ ការនិយាយភាគច្រើនគឺជាភាសាខ្មែរ

នៅពេលដែលយើងធ្វើការទាញយកសំឡេងមកជាអត្ថបទអក្សរ និងវាស់វែងនូវអ្វីដែលនាងបាននិយាយជាក់ស្តែង យើងឃើញថាការនិយាយនោះភាគច្រើនគឺជាភាសាខ្មែរ។ នាងបានប្រើប្រាស់ភាសាអង់គ្លេសសម្រាប់តែពាក្យគន្លឹះខ្លីៗដើម្បីផ្តល់កម្លាំងចិត្តប៉ុណ្ណោះ ដូចជាពាក្យ "trust your gut" (ជឿជាក់លើវិចារណញ្ញាណខ្លួនឯង), "conviction" (ជំនឿចិត្តមុតមាំ) និង "mentality" (ផ្នត់គំនិត) ជាដើម ដែលពាក្យទាំងនេះមានអត្ថន័យធ្ងន់ និងមានឥទ្ធិពលដែលទស្សនិកជនខ្មែររបស់នាងស្គាល់ និងយល់ស្រាប់ទៅហើយ។ របារខាងក្រោមបង្ហាញពីតុល្យភាពនៃភាសាទាំងពីរ នៅក្នុងអត្ថបទសំឡេងទាំងស្រុង។

*សូមពិនិត្យមើល ឧបសម្ព័ន្ធអត្ថបទសំឡេង (transcript) ខាងក្រោម។*

**សមាមាត្រភាសានៃអត្ថបទសំឡេង (transcript)**

ការវាស់វែងដែលធ្វើតាមវិធីសាស្ត្រ syllable-adjustment method



### មតិដើម ដែលឆ្លុះបញ្ចាំងពីការយល់ឃើញចំពោះការនិយាយលាយភាសា

> *"Khmer ❌ English ❌ Khmerlish ✅ "Do you understand the words coming out of my mouth?"😂"*
> — Comment #108 · Mocking · 102 likes

> *"Ok ខ្ញុំdon't យល់"*
> — Comment #507 · Neutral · 1 like

> *"ខ្ញុំdon't understand ន័យបងspeak but ព្យាយាម think 🤔"*
> — Comment #516 · Neutral · 1 like

> *"ការនិយាយលាយលំភាសាបែបនេះ គេហៅថា multilingualism ដែលអ្នកនិយាយ និយាយភាសាពីរលាយគ្នានៅពេលតែមួយ។"*
> — Comment #490 · Neutral · 2 likes

> *"កន្លែងស្រួលនិយាយអង់គ្លេស កន្លែងពិបាកនិយាយខ្មែរ។ ដោយស្មោះត្រង់ខ្ញុំរាល់ថ្ងៃនេះ ចិញ្ចឹមខ្លួនឯង រហូតមានគ្រួសារកូន២ទៅហេីយ រស់បានដោយការប្រេីប្រាស់ភាសាអង់គ្លេស ខ្ញុំប្រេីប្រាស់វា តែក្នុងការងារ ប៉ុណ្ណោះ តែក្នុងទំនាក់ទំនងជាសាធារណៈ ជាមួយជនជាតិខ្មែរ និងខ្មែរ ទោះបីដឹងថាអ្នកឯងចេះអង់គ្លេសក៏ដោយ ខ..."*
> — Comment #5 · Constructive · 12 likes

# ៤. ការពិភាក្សា

លំនាំចំនួនបីនៅក្នុងទិន្នន័យដែលគួរឱ្យយកចិត្តទុកដាក់៖

**ទីមួយ៖** ការបញ្ចេញមតិនេះមិនមែនជា "ការព្រួតគ្នាបង្អាប់" តែម្ខាងនោះទេ។ មតិដែលមានហេតុផល រួមមានមតិក្នុងន័យស្ថាបនា ការគាំទ្រ និងការការពារ — បូកបញ្ចូលគ្នា (៤៦,០%) គឺមានតុល្យភាពស្ទើរតែស្មើគ្នាទៅនឹងសម្លេងប្រឆាំងអ្នកនិយាយ (៤៦,៥%)។ អារម្មណ៍ដែលថា "មនុស្សគ្រប់គ្នាប្រឆាំងនឹងនាង" គឺត្រូវបានបង្កើតឡើងដោយមតិអវិជ្ជមានខ្លីៗមួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែទទួលបានការចុចចូលចិត្ត (Like) ច្រើនលើសលប់ (មធ្យម ៧,៤ ក្នុងមួយមតិ ដែលជាកម្រិតខ្ពស់បំផុតក្នុងចំណោមគ្រប់មតិទាំងអស់) ជាជាងការឆ្លុះបញ្ចាំងពីទស្សនៈរបស់មនុស្សភាគច្រើន។

**ទីពីរ៖** ការរិះគន់ភាគច្រើនគឺផ្តោតលើរបៀបនិយាយ មិនមែនខ្លឹមសារនោះទេ។ ក្នុងចំណោមមតិប្រឆាំងទាំង ៤៦០ ស្ទើរតែគ្មានមតិណាមួយជជែកដេញដោលអំពីសារពិតប្រាកដរបស់អ្នកនិយាយ ដែលជារឿងរ៉ាវអំពីការយកឈ្នះលើការភ័យខ្លាចក្នុងការនិយាយជាសាធារណៈនោះឡើយ។ ការតវ៉ាគឺផ្តោតតែលើការនិយាយលាយឡំគ្នា រវាងភាសាខ្មែរ និងអង់គ្លេស ដែលវាត្រូវបានចាត់ទុកថាជាបញ្ហាទៅហើយ។ នេះគឺជាគោលជំហរ "អភិរក្សភាសានិយម" បែបបុរាណ ហើយវាបានគ្របដណ្តប់លើភាគីប្រឆាំងនៃការបញ្ចេញមតិនេះ។ អ្នកនិយាយ ត្រូវបានគេចោទប្រកាន់ថាបោះបង់ភាសាដែលខ្លួនកំពុងប្រើប្រាស់ជាចម្បង ប៉ុន្តែការពិតដែលថាការនិយាយនេះគឺប្រើប្រាស់ភាសាខ្មែរជាភាគច្រើន (៦០,៨%)។ ប៉ុន្តែទោះជាយ៉ាងណា អ្នកបញ្ចេញមតិទំនងយល់ថា ការប្រើប្រាស់ការនិយាយលាយឡំគ្នាភាសាខ្មែរ និងភាសាអង់គ្លេស អាចនឹងធ្វើឲ្យបាត់បង់ភាសាខ្មែរ។

**ទីបី៖** ទម្រង់នៃការបញ្ចេញមតិនេះដើរតាមលំនាំ "ការបៀតបៀនតាមប្រព័ន្ធអ៊ិនធឺណិត" (Online Harassment) ដែលមានឯកសារស្រាវជ្រាវជាច្រើនបានបង្ហាញ៖ គឺភាពអរិភាពដែលបន្លំខ្លួនក្នុងរូបភាពជាការលេងសើច (រូបសញ្ញាបញ្ចេញអារម្មណ៍សើចចំអក), ការសរសេរបែបចំអក ដូចជាការ "ចំណាងជើងសម្រាប់ការនិយាយរបស់

នាង" (Subtitle), ការប្រើសំណួរបញ្ឆោះក្នុងបំណងបង្អាប់បង្អួច និងការវាយប្រហារបុគ្គលលើកម្រិតបញ្ញា។ ការបញ្ចេញមតិទាំងនេះបានពង្រីកសម្លេងភាគតិចឱ្យមើលទៅហាក់ដូចជា "មតិឯកច្ឆន្ទ" របស់មហាជន។ ដូច្នេះ រាល់ការយល់ឃើញចំពោះការបង្ហោះនេះ ដោយផ្អែកតែលើមតិកំពូលៗ (Top comments) នឹងធ្វើឱ្យមានការវាយតម្លៃលើសពីការពិត អំពីកម្រិតនៃភាពអវិភាព ថាជនជាតិខ្មែរមានទំនោរទៅកាន់ការប្រើប្រាស់ «Khmerlish»។

# ៥. ការសន្និដ្ឋាន

របាយការណ៍នេះមានគោលបំណងបង្ហាញដោយផ្អែកលើភស្តុតាងជាក់ស្តែង ជាជាងការប្រើប្រាស់អារម្មណ៍ស្មាន អំពីរបៀបដែលមហាជនខ្មែរមានប្រតិកម្មចំពោះវីដេអូ របស់ យុវតីខ្មែរឈ្មោះ Keang Dee Kong ឬហៅថា KD ដែលល្បីសុះសាយ (viral) មួយ និងចង់ដឹងថា តើការនិយាយនោះមានសម្លេងយ៉ាងណាឱ្យប្រាកដ។ តាមរយៈការអានមតិយោបល់ទាំង ៩៩០ ស្របតាមបរិបទ បានបង្ហាញឱ្យឃើញពីការបែងចែកទស្សនៈរបស់អ្នកបញ្ចេញមតិ៖ ក្រុមប្រឆាំងដែលមានសម្លេងខ្លាំងៗដោយផ្តោតលើអភិរក្សភាសានិយម, ក្រុមដែលមានចំនួនប្រហាក់ប្រហែលគ្នាដែលផ្តល់ដំបូន្មានដោយស្មោះត្រង់ និងក្រុមអ្នកការពារ និងអ្នកគាំទ្រដែលមានសម្លេងតិចជាង ប៉ុន្តែមានវត្តមានពិតប្រាកដក្នុងការបញ្ចេញមតិទាំងមូល។ ការវាស់វែងលើអត្ថបទសំឡេង (transcript) ដោយផ្ទាល់បានបង្ហាញថា ការនិយាយនោះគឺប្រើប្រាស់ភាសាខ្មែរជាភាគច្រើន ដោយប្រើភាសាអង់គ្លេសសម្រាប់តែពាក្យគន្លឹះខ្លីៗដើម្បីផ្តល់កម្លាំងចិត្តប៉ុណ្ណោះ ដែលចំណុចនេះគឺផ្ទុយស្រឡះពីការលើកឡើងបែបបង្អាប់បង្អួចដែលកំពុងចែកចាយក្នុងផ្នែកមតិយោបល់។

មេរៀនដ៏ល្អដែលយើងទទួលបានគឺថា ការជជែកដេញដោលអំពីភាសា «Khmerlish» ក្នុងផូសរបស់ យុវតីខ្មែរនេះ មិនទាន់មានការឯកភាពគ្នាច្បាស់លាស់ ដូចអ្វីដែលមតិដែលមានសំឡេងច្រើនបានបង្ហាញនោះទេ។ ប្រជាជនខ្មែរមិនមែនសុទ្ធតែប្រឆាំងនឹងការនិយាយលាយឡំភាសានោះទេ ពោលគឺពួកគេកំពុងស្ថិតក្នុងដំណាក់កាលជជែកដេញដោលយ៉ាងសកម្មអំពីទម្រង់នៃអត្តសញ្ញាណទ្វិភាសា ហើយការបញ្ចេញមតិទាំងនោះមានការចូលរួមក្នុងន័យស្ថាបនា ច្រើនដូចគ្នានឹងការសើចចំអកដែរ។ ការសិក្សានៅថ្ងៃអនាគត អាចនឹងយកវិធីសាស្ត្រនេះទៅអនុវត្តលើការផូសដែលល្បីៗខ្លាំងផ្សេងៗទៀត ដើម្បីពិនិត្យមើលថាតើលំនាំដែលរកឃើញនៅទីនេះ គឺជាទិដ្ឋភាពទូទៅដែរឬទេ ហើយក៏អាចបន្ថែមការវិភាគមតិយោបល់នេះ ជាមួយការសម្ភាសអ្នកបញ្ចេញមតិផ្ទាល់ ដើម្បីស្វែងយល់ពីបទពិសោធន៍ដែលពួកគេទទួលបានពីប្រតិកម្មតបតទាំងនោះផងដែរ។

# CODE-SWITCHING IN ACTION

*A color-coded look at how Khmer and English mix in everyday speech*

| KHMER ភាសាខ្មែរ | ENGLISH |
|---|---|

OVERALL LANGUAGE MIX Khmer 60.8% · English 39.2%

## THE TRANSCRIPT (color-coded)

[00:00] **Speaker 1:**

You wanna ចង់ លក់ អនឡាញ Yes go there លក់ អនឡាញ

[00:03] **Speaker 1:**

You need that fire to fuel inside you ដើម្បី បណ្តុះ អា ហ្នឹង មាន conviction to make it done.

[00:08] **Speaker 1:**

ធ្វើ business there is no formula. The only formula is your mentality to make it work.

[00:15] **Speaker 1:**

បង used to fail ពេល បង ចប់ និទ្ទេស A គេ ឲ្យ បង ទៅ share នៅ ក្នុង សាលា

[00:19] **Speaker 1:**

and បង fail publicly in front of 1000 students.

[00:22] **Speaker 1:**

គេ ឲ្យ បង ឡើង ទៅ sharing អំពី how to get grade A.

[00:26] **Speaker 1:**

And you know what? Go there, froze, រឹង ខ្លួន ឡើង ពី ដើម ដល់ ចុង ខ្ញុំ និយាយ លេង ចេញ ខ្ញុំ សុំ ចុះ មក វិញ។

[00:33] **Speaker 1:**

Yeah I publicly publicly fail.

[00:36] **Speaker 1:**

And you know what? បង គិត ថា បង នឹង មិន ជា មនុស្ស ដែល អាច និយាយ នៅ មុខ មនុស្ស ជា ទូទៅ បាន ទេ

[00:42] **Speaker 1:**

បង ខ្លាច មនុស្ស ហ្នង។

[00:44] **Speaker 1:**

ប៉ុន្តែ because of the gut, because of the courage to to ចង់ ឈ្នះ វា

[00:48] **Speaker 1:**

That's why បាន បង និយាយ ថា you need to trust your gut ពីព្រោះ gut ហ្នឹង វា នឹង ប្រាប់ អូន ឯង ថា

[00:53] **Speaker 1:**

វា ដូច អត់ ខុស ពី មនុស្ស ម្នាក់ ទៀត មក ជួយ push អូន ឯង អញ្ចឹង។

[00:57] **Speaker 1:**

And if អូន ឯង ទោរទន់ វា នឹង មក push តែ ទាល់តែ អូន ឯង ស្តាប់ វា ដែរ។

[01:01] **Speaker 1:**

You need to start from somewhere. And sometimes you end up getting better because you felt it.

[01:07] **Speaker 1:**

And fell it big.

[01:09] **Speaker 1:**

So the lessons that I can teach you right now, this worry session, បង can teach you one thing.

[01:16] **Speaker 1:**

Stay grateful of what you have. And get the best out of it.

[01:21] **Speaker 1:**

As much as you can.

## WHAT YOU'RE LOOKING AT

*Code-switching — moving between two languages mid-sentence — is a normal feature of bilingual speech. It is not a sign of weak language ability; it actually requires fluency in both languages.*

In this 1 minute 21 second clip, the speaker actually used Khmer for roughly 60.8% of her syllables — Khmer was her dominant language, not English.